**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខៈ ៤៣២.ស.ជ.ក/គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែ០៩ ឆ្នាំ២០១៦

# សោរពជូន

## ឯកឧត្តមអភិបាលខេត្តបាត់ដំបង កំពង់ចាម កំពង់ស្ពឺ កំពង់ធំ មណ្ឌលគិរី ព្រៃវែង រតនគិរី សៀមរាប ព្រះសីហនុ ស្ទឹងត្រែង ស្វាយរៀង ត្បូងឃ្មុំ និងខេត្តឧត្តរមានជ័យ

**កម្មវត្ថុ** ៖ ការគាំទ្រមូលនិធិឃុំ សង្កាត់សម្រាប់ពង្រឹងកិច្ចដំណើរការមត្តេយ្យសហគមន៍ក្នុងឆ្នាំ២០១៦ ។

**យោង** ៖ ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦របស់លេខាធិការដ្ឋាន គ.ជ.អ.ប. ។

សេចក្ដីដូចបានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្ដមមេត្ដាជ្រាបថា ក្នុងគោលបំណងរួមចំណែកអនុវត្តមុខងារក្នុងវិស័យអប់រំ ក៏ដូចជាលើកកម្ពស់សេវាសង្គមនៅថ្នាក់ក្រោមជាតិ លេខាធិការដ្ឋាន គ.ជ.អ.ប. បានវិភាជមូលនិធិឆ្នាំ២០១៦របស់ខ្លួនមួយចំនួន ដើម្បីគាំទ្រកិច្ចដំណើរការមត្តេយ្យសហគមន៍ក្នុងឃុំគោលដៅដែលធ្លាប់គាំទ្រដោយកម្មវិធីសិទ្ធិកុមារនៃអង្គការ UNICEF កន្លងមក (ដូចមានក្នុងតារាងជូនភ្ជាប់មកជាមួយ) ។ តួលេខនៃការវិភាជនេះ គឺជាព័ត៌មានបឋមសម្រាប់គាំទ្រឃុំគោលដៅនីមួយៗក្នុងកិច្ចដំណើរការមត្តេយ្យសហគមន៍ និងបង្កលក្ខណៈងាយស្រួលដល់ឃុំទាំងនោះអាចបញ្ចូលមូលនិធិនេះទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំ២០១៦របស់ខ្លួនឱ្យបានទាន់ពេលវេលា ។ នៅពេលមូលនិធិគាំទ្រនេះត្រូវបានផ្ទេរពីថ្នាក់ជាតិឱ្យឃុំគោលដៅ ចំនួនមូលនិធិសរុបតាមឃុំនីមួយៗអាចមានការប្រែប្រួលបន្តិចបន្តួច អាស្រ័យលើអត្រាប្ដូរប្រាក់ជាក់ស្ដែងតាមខែនីមួយៗ ដូច្នេះ ឃុំគោលដៅនីមួយៗនឹងត្រូវធ្វើការកែសម្រួលគម្រោងថវិកាឆ្នាំ២០១៦របស់ខ្លួនស្របតាមចំនួនមូលនិធិជាក់ស្ដែងដែលបានទទួល ។

បន្ទាប់ពីទទួលបាននូវព័ត៌មានជាបឋមអំពីកញ្ចប់មូលនិធិសម្រាប់ឆ្នាំ២០១៦ ឃុំគោលដៅនីមួយៗត្រូវរៀបចំបញ្ចូលក្នុងគម្រោងថវិកាឆ្នាំ២០១៦របស់ខ្លួនក្នុង**ជំពូក ៦២** សម្រាប់សកម្មភាពសេវាសង្គមនានា និងក្នុង**អនុគណនី ៦១០៩៣** សម្រាប់ប្រាក់ឧបត្ថម្ភគ្រូមត្តេយ្យសហគមន៍ ។ ចំពោះការប្រើប្រាស់មូលនិធិនេះ គឺត្រូវអនុវត្តតាមគោលការណ៍ និងនីតិវិធីនានាសម្រាប់សេវាសង្គមដែលបានអនុវត្តកន្លងមក ។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូមឯកឧត្ដមមេត្ដាជ្រាប និងណែនាំដល់មេឃុំនៃឃុំគោលដៅ ដើម្បីបញ្ចូលមូលនិធិនេះក្នុងគម្រោងថវិកាឆ្នាំ២០១៦របស់ខ្លួនឱ្យបានត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធភាព ។

សូមឯកឧត្ដមទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ ។

**ចម្លងជូន ៖**

- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានរតនាគារជាតិ
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃរាជធានី ខេត្តគោលដៅទាំង៣
- រតនាគារនៃរាជធានី ខេត្តគោលដៅទាំង៣
- ឯកសារ-កាលប្បវត្តិ

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**